សន្លឹកព័ត៌មាន

Information Sheet – Information for farmers markets – Khmer

# ការលក់ផ្លែឈើ និងបន្លែ

## ព័ត៌មានសម្រាប់ទីផ្សារកសិករ

ការផ្ទុះរាតត្បាតនៃរុយចោះផ្លែឈើនៅរដ្ឋអូស្ត្រាលីខាងត្បូងមានន័យថា ការរឹតបន្តឹងត្រូវបានដាក់ដំណើរការសម្រាប់អាជីវកម្មលក់ផ្លែឈើ និងបន្លែក្នុងតំបន់ដែលមានហានិភ័យពីរុយចោះផ្លែឈើ។  ទាំងនេះត្រូវបានគេហៅថាផលដំណាំដែលផ្តល់ទីជម្រក។

**ផ្សារនេះស្ថិតនៅក្នុងតំបន់ផ្ទុះរាតត្បាតពណ៌ក្រហមសម្រាប់រុយចោះផ្លែឈើ។**

ស្វែងរកទីតាំងដែលការផ្ទុះរាតត្បាតនៃរុយចោះផ្លែឈើ នៅតាម **fruitfly.sa.gov.au/outbreak-map**

## អ្វីដែលអ្នកត្រូវធ្វើ

មានកិច្ចការមួយចំនួនដែលអ្នកត្រូវធ្វើ ប្រសិនបើអ្នកចង់បន្តលក់ផ្លែឈើ និងបន្លែដែលផ្តល់ទីជម្រក (សូមមើលបញ្ជីដែលដាក់ភ្ជាប់មកជាមួយ) នៅក្នុងតំបន់ផ្ទុះរាតត្បាតរុយចោះផ្លែឈើពណ៌ក្រហម។

### ការពារផ្លែឈើ និងបន្លែដែលផ្តល់ទីជម្រកណាមួយ

ការពារបន្លែ និងផ្លែឈើដែលផ្តល់ទីជម្រកណាមួយពីរុយចោះផ្លែឈើ (សូមមើលបញ្ជីផលដំណាំដែលដាក់ភ្ជាប់មកជាមួយ) គ្រប់ពេលវេលា រួមទាំងនៅ ពេលដែលអ្នកចូល លក់ និងចាកចេញពីទីផ្សារ។ វិធីនានាដែលអ្នកអាចការពារបន្លែ និងផ្លែឈើ ពីរុយចោះផ្លែឈើរួមមាន៖

- ✓ ថង់ប្លាស្ទិច (ត្រូវបានចងជាប់ ឬបិទជិតដោយគ្មានប្រហោងធំជាង 1.6 មម)
- ✓ ថាសគ្របដោយបន្ទះប្លាស្ទិករុំខ្ចប់ Cling wrap
- ✓ ប្រអប់ក្រដាសកាតុង បិទភ្ជាប់ជាមួយបង់ស្អិត (គ្មានប្រហោង)
- ✓ ការគ្របផលដំណាំជាមួយសំណាញ់ការពាររុយ
- ✓ ការដឹកជញ្ជូនផលដំណាំក្នុងយានយន្តដែលគ្របបាំងជិត (មិនមែនយានយន្ត utes ឬរថសណ្តោងដែលបើកចំហ)
- ✓ រក្សាផលដំណាំក្រោម 13 អង្សាសេ

### យកតែផលដំណាំដែលអ្នកត្រូវការប៉ុណ្ណោះ

PIRSA ណែនាំយ៉ាងមុតមាំឱ្យអ្នកយកតែផលដំណាំដែលអ្នកត្រូវការសម្រាប់ការលក់ដូរប្រចាំថ្ងៃប៉ុណ្ណោះ។ ប្រសិនបើអ្នកមានបន្លែ និងផ្លែឈើដែលផ្តល់ទីជម្រកច្រើនលើសលប់ ចូរទុកចោលវានៅចុងបញ្ចប់នៃថ្ងៃនោះ វាត្រូវតែបានការពារពីរុយចោះផ្លែឈើនៅទូទាំងការដឹកជញ្ជូន ការផ្ទុក និងការដាក់តាំង លក់នៅទីផ្សារ ដើម្បីយកផលដំណាំរបស់អ្នកទៅក្រៅតំបន់ផ្ទុះរាតត្បាតពណ៌ក្រហម និងពណ៌លឿង។

PIRSA ref: A4573865

**Fruit Fly Hotline 1300 666 010**

fruitfly.sa.gov.au

Government of South Australia
Department of Primary Industries and Regions

## ការទិញលក់ផ្លែឈើ និងបន្លែដែលផ្តល់ទីជម្រក

អ្នកមិនត្រូវលក់ ឬបរិច្ចាគផ្លែឈើ និងបន្លែដែលដាំដុះនៅក្នុងតំបន់ផ្ទុះរាតត្បាតពណ៌ក្រហម ឬតំបន់ដែលត្រូវបានបញ្ឈប់បណ្តោះអាសន្នពណ៌លឿងទេ លុះត្រាតែអ្នកបានទទួលការព្យាបាលដែលត្រូវបានអនុម័តដើម្បីគ្រប់គ្រងរុយចោះផ្លែឈើ ហើយបានទទួលការយល់ព្រមពី PIRSA។ សូមមើលផែនទីការផ្ទុះរាតត្បាតនៅ fruitfly.sa.gov.au/outbreak-map

ស្វែងយល់ពីការរឹតបន្តឹងសម្រាប់ការផ្លាស់ទីផ្លែឈើ និងបន្លែដែលផ្តល់ទីជម្រក។ **មិនត្រូវ**យកផ្លែឈើ និងបន្លែទាំងនេះចេញពីតំបន់ផ្ទុះរាតត្បាតពណ៌ក្រហម និងពណ៌លឿង ឬតំបន់ដែលត្រូវបានបញ្ឈប់បណ្តោះអាសន្នពណ៌លឿងទេ លុះត្រាតែវាត្រូវបានរក្សាទុកដោយគ្របបាំង និងបិទជិតក្នុងអំឡុងពេលផ្ទុក ដាក់តាំង បង្ហាញនៅទីផ្សារ នៅពេលដឹកជញ្ជូនទៅ និងមកពីទីផ្សារ។

## ការបោះចោលបន្លែ និងផ្លែឈើដែលផ្តល់ទីជម្រក



ផ្លែឈើ និងបន្លែដែលមិនចង់បាន ត្រូវតែបានបោះទៅក្នុងធុងសំរាមពណ៌បៃតងរបស់អ្នក។ ប្រសិនបើអ្នកមិនមានលទ្ធភាពប្រើប្រាស់ធុងសំរាមពណ៌បៃតងទេ សូមវេចខ្ចប់កាកសំណល់ក្នុងថង់ពីរជាន់ ហើយដាក់វាចូលទៅក្នុងធុងសំរាមទូទៅ។

# សូមអគុណចំពោះការរួមសហការរបស់អ្នក

ដោយមានជំនួយរបស់អ្នក យើងទាំងអស់គ្នាអាចការពាររដ្ឋអូស្ត្រាលីខាងត្បូងពីរុយចោះផ្លែឈើ។ ប្រសិនបើអ្នកមានចម្ងល់ណាមួយ សូមទូរសព្ទមកយើងតាមលេខ **1300 666 010**។ អ្នកត្រួតពិនិត្យរបស់យើងក៏នឹងមានវត្តមាននៅទីផ្សារផងដែរ ដើម្បីជួយដល់ម្ចាស់តូបជាមួយនឹងសំណួរណាមួយ។

សូមតាមដានព័ត៌មានថ្មីៗ និងស្វែងយល់ពីការរឹតបន្តឹង - ចូលមើលគេហទំព័រ fruitfly.sa.gov.au

# បញ្ជីផ្លែឈើ និងបន្លែដែលមានហានិភ័យសម្រាប់រុយចោះផ្លែឈើរដ្ឋឃ្វីនស្លែន និងមេឌីទែរ៉ាណេ

